## តើនរណា មានសិទ្ធិទទួលសេវាកម្មសុខភាពផ្លូវចិត្តពី OMBUDS ?

លោកអ្នក មានសិទ្ធិទទួលសេវាកម្មសុខភាពផ្លូវចិត្តពី OMBUDS ប្រសិនបើលោកអ្នក មានសិទ្ធិទទួលសេវាកម្ម ផ្នែកសុខភាពផ្លូវចិត្តសាធារណៈ ហើយរស់នៅក្នុងតម្បន់ Clark, Washington ។ ប្រសិនបើលោកអ្នក មានបញ្ហាផ្នែកសេវាកម្ម ដែលលោកអ្នកកំពុងទទួល ហើយគិតថាសិទ្ធិរបស់លោកអ្នកបានទទួលការរំលោភ ឬលោកអ្នកមិនយល់ព្រមនឹងរឿងបដិសេធសេវាកម្ម សូមទាក់ទង OMBUDS ដើម្បីណាត់ពេលជួបគ្នា តាមលេខ ៣៦០/៣៩៧-៨៤៧០ ។

## តើអ្វីទៀតដែលខ្ញុំត្រូវដឹង ?

អង្គការសុខភាពផ្លូវចិត្ត Ombuds :

- ជាអង្គការឯករាជ្យនៃក្រុមសេវិក និងជាប្រព័ន្ធទ្រទ្រង់ជនបទប្រសជ Clark County ។
- ល្វាសតបស្របតាមវ័យ និងលក្ខណះប្រជាប្រិយនៃតម្បន់ Clark County ។
- ជាមុខវិជ្ជាជីវះផ្នែកអប់រំ ។
- អនុវត្តតាមនិយតកម្មការសម្ងាត់ ។
- ទទួលអាជ្ញាប័ណ្ណពី រដ្ឋ Washington ដើម្បីជួយប្រជាជនទាក់ទងនឹងរឿងត្អូញត្អែ ឬរឿងសាទុក្ខ ។

*(ref: WAC 388-865-0255).*

## ពិធីទាក់ទងអង្គការសុខភាពផ្លូវចិត្ត OMBUDS

សូមទូរស័ព្ទទាក់ទងណាត់ពេលជួបគ្នា :



លេខទូរស័ព្ទ :

**360-397-8470**

**Toll Free:**
**866-666-5070**

អង្គការសេវាកម្មសុខភាពផ្លូវចិត្ត Ombuds
បម្រើអឹតគឹតថ្លៃ ។

អាស័យដ្ឋាន :

Clark County Center for Community Health
1601 E Fourth Plain Blvd, Building 17
Vancouver, WA 98661

ការិយាល័យទទួលភ្ញៀវ :

Dept. of Community Services
2nd Floor, Suite C214

អាស័យដ្ឋានប៉ុស្តិ៍ :

Clark County
**Mental Health Ombuds**
c/o The Logical Mind, Ltd.
16420 SE McGillivray Blvd.
Ste. 103 PMB 910
Vancouver, WA 98683

# Clark County
# **Mental Health Ombuds*** 
# Services

# ការការពារសិទ្ធិអតិថិជន
# និង
# តំណោះស្រាយរឿងត្អូញត្អែ
# និង រឿងសាទុក្ខ



* **Ombuds**\’om- -bədz’\ [***SW, lit.,***]
តំណាង : អ្នកសង្កេតការបញ្ហាត្អូញត្អែ ( ដូចជាពីសិស្សានុសិស្ស ឬអតិថិជន ) ស្វែងរករបាយការណ៍ និង ជួយធ្វើយ៉ាងណាឲ្យមានតំណោះស្រាយសមរម្យ (Webster’s New Collegiate Dictionary, 1981).

## តើអង្គការសុខភាពផ្លូវចិត្ត Ombuds ធ្វើអ្វីខ្លះ ?

- ជួយប្រជាជនឲ្យសម្តែងចេញនូវការត្អូញ ត្អែ និង ការសាទុក្ខ ។
- ផ្តល់ការគាំទ្រ ក្នុងការដោះស្រាយរឿងត្អូញត្អែ និង រឿងសាទុក្ខ ។
- ទាក់ទងជាមួយប្រជាជនដទៃ ៗ ទៀត រកដំណោះស្រាយតាមសំណូមពររបស់គេ ។
- ជួយប្រជាជន ក្នុងរឿងតវ៉ា ប្រសិនបើពួកគេ ទទួលការបដិសេធន៍ ឬផ្តាច់សេវាកម្ម ពីប្រព័ន្ធទ្រទ្រង់ នៅ Clark County ។
- ធ្វើជាតំណាង ឬ គាំទ្រពួកគេ នៅក្នុង អង្គសវនាការឲ្យបានសមរម្យ ។
- ផ្តល់របាយការណ៍ និង អនុសាសន៍អំពីដំណោះស្រាយជូនអង្គការសុខភាពផ្លូវចិត្តសាធារណៈ អំពីរឿងធ្វើឲ្យសេវាកម្មបានកាន់តែប្រសើរ ។
- ផ្តល់ការអប់រំ អំពីសិទ្ធិនៃអតិថិជន ។

លោកអ្នកអាចជួយឲ្យអង្គការសេវាកម្មខាងសុខភាពផ្លូវចិត្តសាធារណៈនៅ Clark County តាមការបញ្ចេញសម្លេងរបស់លោកអ្នក កាលណាមានរឿងមិនប្រក្រតី ឬក៏ខុសឆ្គង ។ ជំនួយពីអតិថិជន មានសារសំខាន់ណាស់ ដើម្បីធ្វើឲ្យបានកាន់តែប្រសើរ និង ដើម្បីថែរក្សាគុណភាពនៃអង្គការសេវាកម្មផ្នែកសុខភាពផ្លូវចិត្ត ។

## អ្វីទៅ ហៅថា ការត្អូញត្អែ ?

**ការត្អូញត្អែ** គឺជាការសម្តែងចេញតាមវាចា ឬជាលាយលក្ខណ៍អក្សរពីការខកចិត្តដែលមិនអាចដោះស្រាយបាន រវាងអតិថិជន និងបុគ្គលដែលទាក់ទង ។

## តើអ្វីទៅ ហៅថា ការសាទុក្ខ ?



**ការសាទុក្ខ** គឺជាការត្អូញត្អែដែលសម្តែងចេញជាលាយលក្ខណ៍អក្សរពីភ្នាក់ងារ នៃប្រព័ន្ធទ្រទ្រង់ នៅ Clark County ។

## តើអ្វីទៅ ហៅថា ការតវ៉ា ឬឧទ្ធរណ៍ ?

**ការតវ៉ា** គឺសំណូមពរជាលាយលក្ខណ៍អក្សរ សុំឲ្យប្រព័ន្ធទ្រទ្រង់នៅ Clark County សើរើពិនិត្យរឿងបដិសេធន៍ និង រឿងកាត់ផ្តាច់សេវាកម្ម ។ សូមទូរស័ព្ទទៅ RSN នៅ Clark County ដើម្បីសុំឧទ្ធរណ៍ករណីនោះ តាមលេខ (360) 397-2130 ។

## តើអ្វីទៅ ហៅថា អង្គសវនាការសមរម្យ ?

**អង្គសវនាការសមរម្យ** គឺជាការសើរើពិនិត្យឡើងវិញ ដោយការិយាល័យរដ្ឋ Washington ត្រូវគេរំលោភ ឬក៏ពេលណាដែលរឿងសាទុក្ខណាមួយមិនអាចដោះស្រាយបាន ។ សូមទូរស័ព្ទទៅការិយាល័យរដ្ឋ Washington ផ្នែកសវនាការ តាមលេខ (360) 690-7189 ។

## តើខ្ញុំត្រូវសម្តែងកង្វល់របស់ខ្ញុំ ដូចម្តេច ?

- ដំបូង យកល្អ គួរព្យាយាមដោះស្រាយរឿងត្អូញត្អែរបស់ខ្លួនជាមួយបុគ្គលនោះដោយផ្ទាល់ មុននឹងសាកមធ្យោបាយដទៃៗ ។ ពន្យល់គេពីបញ្ហារបស់ខ្លួន ឲ្យគេដឹងថាតើធ្វើដូចម្តេចទើបល្អសម្រាប់ខ្លួន ហើយនិយាយពីការត្អូញត្អែអំពីអ្វី ឲ្យច្បាស់ ។ ហើយទៀត ប្រាប់ឲ្យច្បាស់ពីរឿងដំណោះស្រាយបែបណា ទើបខ្លួនទទួលបាន ។ ព្យាយាមរកមធ្យោបាយសម្រុះសម្រួលគ្នា ដែលភាគីទាំងសងខាង គឺខ្លួនអ្នក និង គេ អាចពេញចិត្ត ។
- សូមទូរស័ព្ទទៅទីភ្នាក់ងារ ឬទៅប្រព័ន្ធទ្រទ្រង់ នៅ Clark County ជម្រាបពួកគេ ថាលោកអ្នកចង់បំពេញសំណុំរឿងប្តឹងផ្តល់នោះ ។
- ប្រសិនបើលោកអ្នក មិនសប្បាយចិត្តនិងលទ្ធផល ឬក៏ចង់បានចម្លើយតបជាលាយលក្ខណ៍អក្សរ សូមសរសេរពាក្យតវ៉ា ជាលាយលក្ខណ៍អក្សរទម្រង់សាទុក្ខ ហើយផ្ញើជូនទីភ្នាក់ងារ ឬប្រព័ន្ធទ្រទ្រង់ជនបទនា Clark County ។



លោកអ្នក អាចសុំជំនួយពីអង្គការ MH Ombuds តាមតំណាក់ការដូចបានរៀបរាប់ខាងលើ ព្រមទាំងរឿងឧទ្ធរណ៍ និងសំណូមពរធ្វើសវនាការណាមួយ ។